# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | ៖ | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | ៖ | ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | ៖ | អោ អាន |
| **ភាសាដើម** | ៖ | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 28-May-2020, 15:40
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

---

## ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង សំណើរបស់ អោ អាន សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ

---

**<u>អ្នកដាក់ឯកសារ</u>៖**
**សហមេធាវី**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**<u>អ្នកទទួលឯកសារ</u>៖**
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda J. Hollis

**អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

1. តាមរយៈសហមេធាវីរបស់គាត់ (*"មេធាវីការពារក្ដី"*) អោ អាន សូមធ្វើការឆ្លើយតបទៅនឹង *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង សំណើរបស់ អោ អាន សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ("ចម្លើយតប")*[1]។

2. សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា *សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ("សំណើ")*[2] របស់ អោ អាន ធ្វើឡើងមុនពេលកំណត់ ដោយសារបណ្ដឹងសាទុក្ខរបស់គាត់[3] ជំទាស់នឹង "សេចក្ដីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្ដីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន *("សេចក្ដីថ្លែងការណ៍ថ្ងៃទី០៣ ខែមេសា")*[4] កំពុងរង់ចាំការសម្រេចនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[5]។ ទឡ្ហីករណ៍នេះមិនត្រឹមត្រូវទេ ហើយនាំឲ្យមានការភាន់ច្រឡំទៀតផង។ មេធាវីការពារក្ដីបានដាក់ *សំណើ* របស់ខ្លួននៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ រយៈពេលប្រាំពីរសប្ដាហ៍ក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ *បណ្ដឹងសាទុក្ខជាបន្ទាន់ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ("បណ្ដឹងសាទុក្ខជាបន្ទាន់")* របស់គាត់។ ទោះបី ដោយសារមានមូលហេតុនានាដែលមេធាវីការពារក្ដីមិនអាចគ្រប់គ្រងបានក៏ដោយ ក៏*សំណើ*ត្រូវបានជូនដំណឹងត្រឹមតែជាទម្រង់អេឡិចត្រូនិកប៉ុណ្ណោះនៅ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ដោយមានការចម្លងជូនជាមុនដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងភាគីនានា (រួមទាំងសហព្រះរាជអាជ្ញាអន្តរជាតិ) នៅថ្ងៃទី២០ ខែ

---

[1] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង សំណើរបស់ អោ អាន ស្នើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ("ចម្លើយតប")* ឯកសារ **D363/1** ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។

[2] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ("សំណើ")* ឯកសារ **D363** ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[3] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *បណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ឯកសារ **E004/2/1** ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។

[4] អង្គជំនុំជម្រះសាលាដំបូង "សេចក្ដីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្ដីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន" អាចរកមើលបាននៅលើគេហទំព័រ៖ https://eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao។

[5] *ចម្លើយតប* កថាខណ្ឌ ១០។

មីនា ឆ្នាំ២០២០ មកម្ល៉េះ[6]។ ហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានដឹងយ៉ាងច្បាស់ថា *សំណើ* កំពុងរង់ចាំការសម្រេចនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត នៅពេលគាត់ដាក់ *បណ្តឹងសាទុក្ខជាបន្ទាន់* របស់ខ្លួន[7]។

3. *សំណើ* ត្រូវបានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយសារវិធាន ៦៩(២) នៃវិធានផ្ទៃក្នុង *("វិធាន")* ចែងថា ការិយាល័យសហចៅក្រមស៊ើបអង្កេតជាអ្នកបោះត្រាលើសំណុំរឿងនៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះ និងរក្សាទុកសំណុំរឿងដែលបានលើកលែងចោទប្រកាន់ទៅក្នុងបណ្ណសារ ដូចក្នុងករណីសំណុំរឿងនេះ។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបញ្ជាក់បែបនេះដែរ នៅពេលដែលចៅក្រមទាំងនោះលើកឡើងថា "ក្រឡាបញ្ជីនៃ [អង្គបុរេជំនុំជម្រះ] បានដាក់ឯកសារ និងការណែនាំពីការជូនដំណឹងភ្លាមៗទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] និងភាគីនៅក្នុងសំណុំរឿង ០០៤/២ ក្រោយពេលចេញសេចក្តីពិចារណារួច"[8]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ដោយប្រយោលចំពោះជំហរនេះ ដោយលើកឡើងថា អង្គជំនុំជម្រះមិនបានទទួលសំណុំរឿង និងពុំមានអំណាចគតិយុត្តិក្នុងការទទួលយកសំណុំរឿងនេះទេ[9]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកសំណុំរឿង ០០៤/២ ទេ ដោយសារការិយាល័យសហចៅក្រមស៊ើបអង្កេតមិនទាន់បានបញ្ចប់នីតិវិធីដែលកំណត់ដោយវិធាន ៦៩(២) នៅឡើយ។ ហេតុនេះ គឺ *បណ្តឹងសាទុក្ខជាបន្ទាន់* របស់សហព្រះរាជអាជ្ញាអន្តរជាតិទៅវិញទេដែលបានដាក់មុនពេលកំណត់ ដោយសារគាត់កំពុងព្យាយាមប្តឹងសាទុក្ខជំទាស់ទៅនឹង "សេចក្តីសម្រេច" ដែលមិនទាន់បានសម្រេច (មិនអាចសម្រេចបាន) នៅឡើយ។

4. ជាងនេះទៀត ដូចដែលបានពន្យល់នៅក្នុង *លិខិតឆ្លើយតបពាក់ព័ន្ធនឹងចម្លើយតបរបស់គាត់ទៅនឹង*

---

[6] ការឆ្លើយឆ្លងតាមអ៊ីមែលក្នុងនាមសហមេធាវី ពាក់ព័ន្ធនឹងការចម្លងជូនជាមុននូវសំណើរបស់ អោ អាន សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ មានភ្ជាប់ជាឧបសម្ព័ន្ធ ១។

[7] ការឆ្លើយឆ្លងតាមអ៊ីមែលពីសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងការចម្លងជូនជាមុននូវបណ្តឹងសាទុក្ខជាបន្ទាន់របស់គាត់ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ មានភ្ជាប់ជាឧបសម្ព័ន្ធ ២។

[8] ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ *អនុស្សរណៈអន្តរការិយាល័យ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងការបញ្ជូនសំណុំរឿង ០០៤/២* ឯកសារ **D359/36 & D360/45** កថាខណ្ឌ ៨។

[9] ការឆ្លើយឆ្លងតាមអ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគីពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២ ឯកសារ **D359/36.2 & D360/45.2** ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។ ការឆ្លើយឆ្លងតាមអ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគីពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២ ឯកសារ **D359/36.8 & D360/45.8** ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

*បណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* របស់ អោ អាន ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ គឺថា បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចទទួលយកបានទេ ហើយពុំមានមូលដ្ឋានសំអាងទៀតផង[10]។

5. ចុងក្រោយ នៅក្នុង *ចម្លើយតប* សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងមិនត្រឹមត្រូវម្តងទៀតថា "មានតែសំឡេងភាគច្រើនលើសលុបដែលបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ដែលអាចរារាំងរឿងក្ដីនេះមិនឲ្យដំណើរការទៅជំនុំជម្រះបាន" ហើយគាត់ក៏យល់ខុសអំពីគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ*[11]។ គាត់នៅតែបន្តបដិសេធនូវអត្ថិភាពនៃ*ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ("ដីកាសម្រេចលើកលែងចោទប្រកាន់")*[12] និងយោបល់របស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះនៅក្នុង *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍")*[13]។

6. ដូចដែលមេធាវីការពារក្ដីធ្លាប់បានធ្វើការជំទាស់ពីមុន ហើយដែលបានដាក់បញ្ចូលទៅក្នុងការឆ្លើយតបនេះដែរ[14] គឺថា សំណុំរឿងរបស់ អោ អាន ត្រូវបានរំលត់ជាធរមានរួចទៅហើយ នៅពេល

---

[10] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចទទួលយកបានទេ អនុលោមតាមវិធាន ១០៤(៤)(ក) ឬ ទៅតាមយុត្តាធិការដែលមានស្រាប់របស់អង្គជំនុំជម្រះតុលាការកំពូល។ *លិខិតឆ្លើយតបពាក់ព័ន្ធនឹងចម្លើយតបរបស់ អោ អាន ទៅនឹងបណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ("លិខិតឆ្លើយតប")* ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ មានភ្ជាប់ជាឧបសម្ព័ន្ធ ៣។

[11] *ចម្លើយតប* កថាខណ្ឌ ១១-១២។

[12] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ("ដីកាសម្រេចលើកលែងចោទប្រកាន់")* ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[13] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៦០) *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍")* ឯកសារ **D359/24 & D360/33** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[14] *លិខិតឆ្លើយតប*។ *សំណើ*។ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៦០) *ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង សំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ* ឯកសារ **D359/31 & D360/40** ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៦០) *ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* ឯកសារ **D359/26 & D360/35** ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។ ក្រុមមេធាវីការពារក្ដី អោ អាន *"សំណើសុំការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកសំណុំរឿង ០០៤/២ តាមផ្លូវ*

ចេញ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*[15] ដែលមិនបានច្រានចោល *ដីកាសម្រេចលើកលែងចោទប្រកាន់*[16]។ ការលើកលែងចោទប្រកាន់នេះនៅធរមាននៅឡើយ អនុលោមតាមវិធាន ៧៧(១៣)(ក) និងទៅតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទោះបី *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ក៏នៅមានជាធរមាននៅឡើយ អនុលោមតាមវិធាន ៧៧(១៣)(ខ) ក៏ដោយ ក៏វាមិនមានឥទ្ធិពលទៅលើសុពលភាពនៃ *ដីកាសម្រេចលើកលែងចោទប្រកាន់*ទេ។ សេចក្តីថ្លែងការណ៍ថ្ងៃទី០៣ ខែមេសា ដោយអង្គជំនុំជម្រះសាលាដំបូងគាំទ្រដល់ជំហររបស់មេធាវីការពារក្តី ដោយបញ្ជាក់ថា សំណុំរឿងរបស់ អោ អាន ត្រូវបានបញ្ចប់ជិតប្រាំមួយខែមកហើយ។

7. ហេតុនេះ ដំណាក់កាលដែលនៅសេសសល់ក្នុងសំណុំរឿង ០០៤/២ គឺការបោះត្រា និងរក្សាទុកសំណុំរឿងនេះក្នុងបណ្ណសារប៉ុណ្ណោះ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំដោយគោរពសូមឱ្យសហចៅក្រមស៊ើបអង្កេតមេត្តាបដិសេធចោលទឡ្ហីករណ៍នានានៅក្នុង *ចម្លើយតប* ហើយអនុលោមតាវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុង សូមឱ្យបោះត្រា និងរក្សាទុកសំណុំរឿងនេះក្នុងបណ្ណសារ ឱ្យបានឆាប់រហ័ស។

សូមលោកចៅក្រមមេត្តាទទួលយកការឆ្លើយតបនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០

**សហមេធាវីការពារក្តី អោ អាន**

| | | |
|---|---|---|
| មុំ លុយ្ស | Richard ROGERS | Göran SLUITER |

---

*ច្បាប់ទេ ឬជាជម្រើសម្យ៉ាងទៀត សំណើសុំការពន្យារពេល និងការណែនាំពីការដាក់អញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ មានភ្ជាប់ជាឧបសម្ព័ន្ធ ៤។

[15] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*។

[16] *ដីកាសម្រេចលើកលែងចោទប្រកាន់*។